# ជំពូកទី ៨: ការពិគ្រោះយោបល់ និងការស្ទង់មតិពីសាធារណជន

## ៨.១ គោលបំណង

គោលបំណងនៅក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈ ជាមួយអ្នកដែលពាក់ព័ន្ធ ក្នុងដំណាក់ការសិក្សាសមិទ្ធិលទ្ធភាពរបស់គំរោង គឺដើម្បីផ្សព្វផ្សាយព័ត៌មានគំរោង ប្រមូលយោបល់ផ្សេងៗ ឬក៏ចូលរួមជាគំនិតពីអ្នកដែលពាក់ព័ន្ធទាំងឡាយ ដើម្បីកែលំអផែនការរបស់គំរោង និងការស្ថាបនាគំរោង និងធ្វើឱ្យការអនុវត្តគំរោងប្រព្រឹត្តិទៅដោយរលូន។

ការចូលរួមកិច្ចប្រជុំនេះប្រកបដោយជោគជ័យតាមរយៈកិច្ចសម្ភាសន៍ជាមួយអ្នកចូលរួមនីមួយៗផ្តោតទៅលើក្រុមគោលដៅ (គ្រួសារ និងស្ថាប័នដែលពាក់ព័ន្ធ) និងអ្នកដែលពាក់ព័ន្ធផ្សេងៗទាំងអស់ក្នុងកំឡុងពេលការសិក្សាសមិទ្ធិលទ្ធភាពរបស់គំរោង។ ជាងនេះទៅទៀតកិច្ចពិគ្រោះយោបល់នេះត្រូវបានបើកឱកាសឱ្យអ្នកដែលប៉ះពាល់ផ្ទាល់ និងស្ថាប័នដែលពាក់ព័ន្ធមានឱកាសផ្តល់ជាយោបល់ផ្សេងៗទៅលើគំរោងតាមរយៈការប្រជុំ។

## ៨.២ វិធីសាស្ត្រ

វិធីសាស្ត្រជាទូទៅត្រូវបានប្រើប្រាស់នៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ និងការប្រជុំជាមួយអ្នកដែលពាក់ព័ន្ធនោះគឺ:

- រៀបចំលិខិតអនុញ្ញាតសំរាប់ការសិក្សាតាមតំបន់គំរោងពីក្រសួងបរិស្ថាន និងខេត្តកោះកុង។
- ធ្វើការជ្រើសរើសអ្នកដែលពាក់ព័ន្ធសំខាន់ៗ និងប្រជាជនដែលប៉ះពាល់ផ្ទាល់។
- ធ្វើការណាត់ជួបជាមួយមនុស្សសំខាន់ៗដែលពាក់ព័ន្ធ។
- រៀបចំការប្រជុំជាមួយនឹងប្រជាជនដែលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋាននៅក្នុងសហគមន៍ ជាពិសេសសំរាប់ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីមួយ។
- រៀបចំការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរជាមួយថ្នាក់ខេត្ត។
- ធ្វើលិខិតអញ្ជើញ និងរៀបចំសម្ភារៈឡើងបង្ហាញ។
- ចែកខិតប័ណ្ណ និងផ្សព្វផ្សាយព័ត៌មានតាមវិទ្យុបានដល់សហគមន៍ និងខេត្តមុនពេលកិច្ចប្រជុំចាប់ផ្តើម។
- រៀបចំថតរូប និងអ្នកកត់ត្រារាល់សកម្មភាពទាំងអស់នៅក្នុងកិច្ចប្រជុំ។
- កត់កំណត់ហេតុពីលទ្ធផលទាំងអស់ដើម្បីរៀបចំចងក្រងសំរាប់របាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន (EIA)។

Draft

## ៨.៣ ការស្ទាបស្ទង់មតិពីសាធារណជន

កិច្ចប្រជុំត្រូវបានធ្វើឡើង២លើកក្នុងអំឡុងពេលសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)។ នៅក្នុងគោលបំណងលើកទី១ គឺដើម្បីបញ្ជ្រាបព័តិមានគំរោងទៅដល់សហគមន៍មូលដ្ឋាន និងពិនិត្យមើលបញ្ហាបរិស្ថាន ដែលនឹងអាចកើតមានឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គំរោង។ ការរៀបចំកិច្ចប្រជុំត្រូវបានធ្វើឡើងតាមរយៈអ្នកដឹកនាំសហគមន៍នៅក្នុងឃុំ និងកិរិតថ្នាក់ភូមិ។

កិច្ចប្រជុំលើកទី២ ត្រូវបានរៀបចំបន្ទាប់ពីការបញ្ចប់ការងារចុះសិក្សានៅទីវាលក្នុងតំបន់គំរោង និងប្រមូលលទ្ធផលសិក្សាដ៏ត្រឹមត្រូវគ្រប់គ្រាន់ សិក្សាគំរោងវិស្វកម្ម និងសិក្សាហេតុប៉ះពាល់បរិស្ថានរបស់គំរោងដើម្បីបង្ហាញទៅអ្នកដែលពាក់ព័ន្ធ។ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញអ្នកដែលពាក់ព័ន្ធមួយចំនួនដូចជា តំណាងមកពីសហគមន៍ដែលប៉ះពាល់ គ្រប់មន្ទីរពាក់ព័ន្ធនៅក្នុងខេត្ត វិស័យឯកជននានា អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នផ្សេងៗទៀតមកពីទីក្រុងភ្នំពេញដែលពាក់ព័ន្ធទៅនឹងគំរោងក៏ត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ។

សកម្មភាពពិស្តារ និងលទ្ធផលនៃកិច្ចប្រជុំនីមួយៗត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌដូចខាងក្រោមៈ

### ៨.៣.១ ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

ឃុំចំនួន២ត្រូវបានជ្រើសរើសសំរាប់ការប្រជុំពិគ្រោះយោបល់លើកទី១ ដែលធ្វើឡើងដាច់ដោយឡែកពីគ្នា គឺឃុំឫស្សីជ្រុំ ស្រុកថ្មបាំង និងឃុំតាតៃក្រោម ក្នុងស្រុកកោះកុង។ ព័តិមានពិស្តារសំរាប់កិច្ចប្រជុំនឹងបង្ហាញជូននៅក្នុងតារាង ៨.៣.១-១ ដូចខាងក្រោម។

តារាង ៨.៣.១-១: សកម្មភាពពិស្តារសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

| ល.រ | សកម្មភាព | កំណត់សំគាល់ |
|---|---|---|
| ១ | **មុនពេលប្រជុំ** | |
| ១.១ | រៀបចំអ្នកភូមិ ឬអ្នកដែលចូលរួម រៀបចំទីកន្លែងតាមឃុំនីមួយៗនៃឃុំឫស្សីជ្រុំ ស្រុងថ្មបាំង និងឃុំតាតៃក្រោម ក្នុងស្រុកកោះកុង ខេត្តកោះកុង | ធ្វើការរៀបចំមុនកិច្ចប្រជុំ ២ ឬ៣ថ្ងៃ |
| ២ | **ក្នុងអំឡុងពេលប្រជុំ** | |
| ២.១ | ចុះឈ្មោះអ្នកចូលរួមដោយមានផ្តិតមេដៃ | ៨:០០- ៨:៣០ ព្រឹក |
| ២.២ | តំណាងក្រុមសំរបសំរួលបានណែនាំឱ្យស្គាល់គ្នា និងបង្ហាញពីគោលបំណងនៃអង្គប្រជុំ និងមានថតរូបទុកជាភស្តុតាង | |
| ២.៣ | ធ្វើការផ្សព្វផ្សាយព័តិមានគំរោងដល់អង្គប្រជុំដោយៈ ឧទ្ទេសនាម ចែកជូនឯកសារ និងបង្ហាញជូននូវទីតាំងគំរោងតាមរយៈផែនទី និងសង្ខេបគំរោង(•) | ៨:៣០- ៩:៣០ ព្រឹក |

| | | |
|---|---|---|
| ២.៤ | បំផុសគំនិត និងសួរសំណួរអំពីការយល់ដឹងពីគំរោងពីអ្នកចូលរួម. ចូលរួមជាគំនិតយោបល់ និង សំណួរផ្សេងៗ។ ក្នុងពេលនោះដែរ អង្គប្រជុំបានសំរាករយៈពេលខ្លីដើម្បីពិសានំ និងទឹកបរិសុទ្ធ។ | ៩:៣០- ១១:០០ ព្រឹក |
| ២.៥ | ចំលើយខ្លះបានឆ្លើយតប និងកត់ត្រារាល់សំនួរ និងមតិយោបល់របស់អ្នកចូលរួមទៅក្នុងរបាយការណ៍។ | |

**កំណត់សំគាល់:** (•)ព័តិមានសង្ខេបគំរោងមានបន្ថែមជូនជាភាសាខ្មែរនៅក្នុង( ឧបសម្ព័ន្ធទី៧) និងបង្ហាញផែនទីអាងស្តុកទឹកដែលបានស្នើឡើងជាមួយកំរិតកំពស់ទឹកអតិបរមា និងសមាសធាតុពង្រាងផ្សេងៗទៀត។

ការប្រជុំពិគ្រោះយោបល់ជាមួយសាធារណជននៅក្នុងឃុំឫស្សីជ្រុំ ត្រូវបានធ្វើឡើងនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ នៅក្នុងវត្តសិលាមុន្នីគីរីវង្សី (ដែលគេនិយមហៅថាវត្តថ្មបាំង) ដែលស្ថិតនៅក្នុងភូមិត្រពាំងឈើត្រាវ ជិតសាលាឃុំឫស្សីជ្រុំ ហើយមានចំងាយប្រហែល១៥គ.ម ពីផ្នែកខាងលើនៃតំបន់អាងស្តុកទឹកដែលបានស្នើដោយគំរោង។

រីឯកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនៅក្នុងឃុំតាតៃក្រោម អង្គប្រជុំបានប្រព្រឹត្តទៅនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅក្នុងការិយាល័យសមាគមអេកូទេសចរណ៍តាតៃក្រោម ដែលស្ថិតនៅក្នុងភូមិតាតៃក្រោម ក្បែរសាលាឃុំតាតៃក្រោម ហើយមានចម្ងាយប្រហែល ១០គ.ម ពីផ្នែកខាងក្រោមនៃអគារផលិតថាមពលអគ្គិសនីរបស់គំរោង។

ទីកន្លែងប្រជុំ និងពេលវេលានៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១ ត្រូវបានបង្ហាញជូននៅក្នុងតារាង ៨.៣.១-២ និងលទ្ធផលនៃកិច្ចប្រជុំបានរៀបរាប់នៅក្នុងតារាង ៨.៣.១-៣ និង៨.៣.១-៤។

តារាង ៨.៣.១-២: ទីតាំង, ពេលវេលាប្រជុំ និងអ្នកចូលរួមប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

| ថ្ងៃ ខែ ឆ្នាំ | ទីតាំងប្រជុំ | | | | ចំនួនអ្នកចូលរួមប្រជុំ |
|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ទីកន្លែងប្រជុំ | |
| ០៣ កុម្ភៈ ០៩ | កោះកុង | ថ្មបាំង | ឫស្សីជ្រុំ | វត្តថ្មបាំង ភូមិត្រពាំងឈើត្រាវ | ៥៩នាក់/ស្រី២៨នាក់ |
| ០៧ មេសា ០៩ | កោះកុង | កោះកុង | តាតៃក្រោម | នៅក្នុងការិយាល័យសមាគមអេកូទេសចរណ៍តាតៃក្រោម | ៥៨នាក់/ស្រី៣៨នាក់ |

**សំគាល់:** សូមមើលបញ្ជីឈ្មោះអ្នកចូលរួមលំអិតនៅក្នុងឧបសម្ព័ន្ធទី ៨។

តារាង ៨.៣.១-៣: លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីមួយនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឃុំឫស្សីជ្រុំ នៅក្នុងវត្តថ្មបាំង ។

| ឈ្មោះអ្នកចូលរួម | មុខរបរ និងទីកន្លែង | គំនិត អនុសាសន៍ និងសំនួរ |
|---|---|---|
| អ្នកស្រី ជុំ ផល | កសិករ ភូមិគគីជ្រុំ | - សព្វថ្ងៃនេះគ្រួសាររបស់ខ្ញុំរកប្រាក់ចំណូលដោយសារអនុផលព្រៃឈើនៅក្នុងតំបន់គំរោងនេះ ។<br>- ប្រសិនបើសកម្មភាពរបស់គំរោងធ្វើឱ្យខូចខាតអនុផលព្រៃឈើទាំងនេះតើម្ចាស់គំរោង និងរដ្ឋាភិបាលមានដំណោះស្រាយអ្វីខ្លះដល់ពួកយើងខ្ញុំ? |
| លោក អ៊ូច ច្រឹក | កសិករ ភូមិត្រពាំងឈើត្រាវ | - កសិករមួយចំនួនតែងតែនេសាទត្រីនៅក្នុងស្ទឹងតាតៃ ដូច្នេះនៅពេលគំរោងដំណើរការ តើវាមានផលប៉ះពាល់ទៅដល់ត្រីនៅក្នុងតំបន់ ឬអត់?<br>- ប្រសិនបើគំរោងមានផលប៉ះពាល់ទៅលើធនធានត្រីនៅទីនេះតើម្ចាស់គំរោង និង រាជរដ្ឋាភិបាលមានវិធានការទប់ស្កាត់អ្វីខ្លះដើម្បីដោះស្រាយបញ្ហាប៉ះពាល់ទាំងនេះ? |
| បងស្រី ទេស សុគន្ធ | កសិករ ភូមិគគីជ្រុំ | តើគំរោងនេះបានពន្លិចភូមិរបស់ខ្ញុំ ឬដីរបស់ខ្ញុំ ឬទេ? |
| បងស្រី អ៊ុក សុន | កសិករ ភូមិត្រពាំងឈើត្រាវ | - បងស្រីបានស្នើសុំឱ្យម្ចាស់គំរោងជ្រើសរើសយកកម្មករក្នុងស្រុកពិសេសនៅក្នុងស្រុកថ្មបាំង នៅពេលណាដែលគំរោងចាប់ផ្តើមសាងសង់ ។ |
| លោក ម៉េង រ៉ា | ប្រធានក្រុមប្រឹក្សាឃុំ. ឃុំឫស្សីជ្រុំ | - លោកប្រធានបានស្នើសុំឱ្យម្ចាស់គំរោងផ្តល់អ្នកជំនាញបច្ចេកទេសផ្សព្វផ្សាយកសិកម្ម ជួយបណ្តុះបណ្តាលដល់អ្នកភូមិអំពីការចិញ្ចឹមសត្វ និងការដាំដំណាំផង ។ |
| ប្រជាជន | ក្នុងស្រុកថ្មបាំង | - ស្នើសុំម្ចាស់គំរោងឱ្យផ្តល់ថាមពលអគ្គិសនីដែលមានតម្លៃថោកដល់ប្រជាជនក្នុងស្រុកថ្មបាំងបានប្រើប្រាស់ផង ។ |
| អ្នកចូលរួមទាំងអស់ | ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង | - បានស្នើសុំឱ្យអ្នកអនុវត្តគំរោងក៏ដូចជាម្ចាស់គំរោងជួយជួសជុលផ្លូវថ្មបាំងពីទីប្រជុំជនផ្លូវប្រសព្វលេខ៤៨ទៅទីរួមស្រុកថ្មបាំង ។ |

សំណួរដ៏ច្រើនលើសលប់ត្រូវបានឆ្លើយតបដោយក្រុមសិក្សាក្រោយពីសំណួរនីមួយៗបានបញ្ចប់ ។ ប្រជាជនបានយល់ច្បាស់អំពីស្ថានភាពរបស់គំរោង និងសកម្មភាពរបស់វា ។

អ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំបានគាំទ្រគំរោង១០០% និងចង់ឱ្យគំរោងមានដំណើរការឆាប់រហ័ស ។

Draft



រូបភាព ៨.៣.១ក: សកម្មភាពនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង

តារាង ៨.៣.១-៤: លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈក្នុងថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅក្នុងការិយាល័យសមាគមអេកូទេសចរណ៍តាតៃក្រោម។

| **ឈ្មោះអ្នកចូលរួម** | **មុខរបរ និងទីកន្លែង** | **គំនិត អនុសាសន៍ និងសំណួរ** |
|---|---|---|
| លោក កែវ ប៊ុនធឿន | កសិករ ភូមិអន្លង់វ៉ាក់ | - លោកព្រួយបារម្ភខ្លាចដាច់ទំនប់ក្នុងអំឡុងពេលប្រតិបត្តិការ<br>- តើទំនប់វារីអគ្គិសនីនោះគេសាងសង់យ៉ាងដូចម្តេច? |
| លោក ឡាយ អេម | ប្រជាជន ភូមិអន្លង់វ៉ាក់ | - បន្ទាប់ពីការបញ្ចប់នៃការសាងសង់ទំនប់នេះ តើវាមានផលប៉ះពាល់ទៅដល់ត្រីនាគ ឬទេ? |
| លោក សាំ ចឺរ | ប្រជាជន ភូមិអន្លង់វ៉ាក់ | - លោកខ្លាចបាក់ទំនប់ ប្រសិនបើមានរឿងនេះកើតមានឡើង តើមានផលប៉ះពាល់ដល់អ្នករស់នៅក្នុងភូមិទាំងមូលឬទេ? |
| លោក ខៀវ នាង | ប្រជាជន ភូមិអន្លង់វ៉ាក់ | - លោកខ្លាចដាច់ទំនប់ បើអញ្ចឹងមែនគឺអ្វី១ត្រូវបានបញ្ចប់គ្មានអ្វីនៅសេសសល់ទេ។ |
| អ្នកស្រី មុំ ផាន | ប្រជាជន<br>ភូមិកោះអណ្តែត | - បងស្រីបានស្នើសុំទៅម្ចាស់គំរោងត្រូវសាងសង់ទំនប់ឱ្យបានឆាប់បើអាចធ្វើទៅបាន។<br>- ក្នុងពេលប្រតិបត្តិការគំរោងសុំមេត្តាផ្គត់ផ្គង់ភ្លើងអគ្គិសនីឱ្យអ្នកភូមិប្រើប្រាស់ និងមានតម្លៃថោងជាងសព្វថ្ងៃផង។ |
| លោក ខៀវ ណន | មេឃុំតាតៃក្រោម | - លោកព្រួយបារម្ភពីការពន្លិចទឹកធ្វើឱ្យជំនន់នៅរដូវប្រាំង |
| លោក ស៊ុន ស៊ីម | ប្រជាជន ភូមិអន្លង់វ៉ាក់ | - តើពេលណាទៅបានគំរោងសាងសង់? |

| | | |
|---|---|---|
| លោក ហេង ហួន | ប្រធានភូមិអន្លង់វ៉ាក់ | - ក្នុងអំឡុងពេលគំរោងប្រតិបត្តិការ វាមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់អ្នកភូមិ ជាពិសេសអ្នកនេសាទ តើគេដោះស្រាយយ៉ាងដូចម្តេចចំពោះបញ្ហានេះ? |
| លោក វង់ អ៊ុន | ប្រជាជន ភូមិកោះអណ្តែត | - ស្នើសុំឱ្យម្ចាស់គំរោងសាងសង់ទំនប់ឱ្យបានឆាប់បើអាចធ្វើទៅបាន។ |
| លោកស្រី ចេនទិត ញូម៉ែន | ប្រជាជន ភូមិអន្លង់វ៉ាក់ | - ប្រសិនបើមានការជំទាស់មួយចំនួនពីប្រជាជន តើគំរោងនឹងត្រូវបានពិចារណាថាតើគួរធ្វើ ឬមិនធ្វើទេ?<br>- តើទឹកមានការប្រែប្រួលយ៉ាងដូចម្តេចនៅរដូវរាំងស្ងួត និងរដូវភ្លៀងធ្លាក់?<br>- គំរោង នឹងប៉ះពាល់ដល់ជីវិតសត្វរស់នៅក្នុងទឹក តើគេដោះស្រាយបញ្ហាដែលប៉ះពាល់យ៉ាងដូចម្តេចខ្លះ? |

សំណួរដ៏ច្រើនលើសលប់ត្រូវបានឆ្លើយតបដោយក្រុមសិក្សា។ ប្រជាជនបានយល់ច្បាស់អំពីស្ថានភាពរបស់គំរោង និងសកម្មភាពរបស់វា។ ពួកគេសង្ឃឹមថា សហគមន៍របស់ពួកគេនឹងមានភ្លើងអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់នឹងមានតម្លៃថោក ក្រោយពីបញ្ចប់គំរោងសាងសង់។

អ្នកចូលរួមទាំងអស់នៅក្នុងអង្គប្រជុំបានគាំទ្រគំរោង១០០% និងចង់ឱ្យគំរោងមានដំណើរការឆាប់រហ័ស



រូបភាព ៨.៣.១ខ: សកម្មភាពនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ នៅឃុំតាតៃក្រោម ស្រុកកោះកុង

Draft

## ៨.៣.២ ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២

ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ស្ថិតនៅក្នុងសាលាខេត្តកោះកុង។ អ្នកចូលរួមមកពី (១) អាជ្ញាធរដែនដីក្នុងតំបន់គំរោងមានដូចជា មេភូមិ និងអនុភូមិ ក្រុមប្រឹក្សាឃុំ សមាគម ប៉ូលីស (២) មន្ទីរដែលពាក់ព័ន្ធថ្នាក់ខេត្ត (៣) ខុទ្ទកាល័យខេត្ត (៤) អង្គការមិនមែន

រដ្ឋាភិបាលមួយចំនួន (៥) តំណាងវិស័យឯកជន និង(៦) តំណាងមកពីអន្តរក្រសួងមកពីកំរិតថ្នាក់ជាតិ។ ការរៀបចំរដ្ឋអំណាចមូលដ្ឋានរួមមាន មេភូមិ និងអនុភូមិ ក្រុមប្រឹក្សាឃុំ និងស្រុក និងធ្វើការអញ្ជើញមន្ទីរសំខាន់ៗ ថ្នាក់ខេត្ត និងតំណាងឱ្យថ្នាក់ជាតិនៅភ្នំពេញ។ លទ្ធផលពិស្តារពីកម្មវិធីប្រជុំ និងបញ្ជីឈ្មោះអ្នកចូលរួមមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី ៨។

សកម្មភាពពិស្តារពីការប្រជុំ ទីកន្លែង និងចំនួនអ្នកចូលរួមត្រូវបានរៀបរាប់ក្នុងតារាង ៨.៣.២-១ និង៨.៣.២-២ ខាងក្រោម។

តារាង ៨.៣.២-១: សកម្មភាពពិស្តារសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២។

| ល.រ | សកម្មភាព | កំណត់សំគាល់ |
|---|---|---|
| ១ | **មុនពេលប្រជុំ** | |
| ១.១ | ស្នើសុំការអនុញ្ញាតពីអភិបាលខេត្តកោះកុងដើម្បីយល់ព្រមពីថ្ងៃប្រជុំ និងទីតាំង។ អញ្ជើញអភិបាលខេត្តជាគណៈអធិបតីនៃអង្គប្រជុំ។ រៀបចំទីកន្លែងប្រជុំក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង | ស្នើសុំទៅខុទ្ទកាល័យខេត្ត ២អាទិត្យមុនថ្ងៃប្រជុំ |
| ១.២ | រៀបចំលិខិតអញ្ជើញទៅអ្នកដែលពាក់ព័ន្ធសំខាន់ៗនៅក្នុងមណ្ឌល និងកំរិតថ្នាក់ខេត្ត រួមទាំងថ្នាក់ដឹកនាំសហគមន៍ក្នុងតំបន់គំរោង និងវិស័យឯកជនត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ។ | ១អាទិត្យមុនថ្ងៃប្រជុំ |
| ១.៣ | ធ្វើការបញ្ជាក់បន្ថែមក្នុងការប្រជុំតាមរយៈអ៊ីម៉ែល និងទូរស័ព្ទ | ៣ឬ២ថ្ងៃមុនពេលប្រជុំ |
| ២ | **ក្នុងអំឡុងពេលប្រជុំ** | |
| ២.១ | ចុះឈ្មោះអ្នកចូលរួមដោយមានចុះហត្ថលេខា និងលេខទូរស័ព្ទរបស់អ្នកចូលរួម | ៨:០០- ៨:៣០ ព្រឹក |
| ២.២ | តំណាងក្រុមសំរបសំរួលបានណែនាំឱ្យស្គាល់គ្នា និងបង្ហាញពីគោលបំណងនៃអង្គប្រជុំ និងមានថតរូបទុកជាភស្តុតាង | |
| ២.៣ | សំណេះសំណាលបើកកម្មវិធីដោយប្រធានអង្គប្រជុំ | ៨:៣០- ៨:៤០ ព្រឹក |
| ២.៤ | បង្ហាញអំពីលទ្ធផលសិក្សាព្រមទាំងគំរោងវិស្វកម្ម និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយក្រុមសិក្សាស្រាវជ្រាវ (CHMC/CTHL, NWH, and KCC) | ៨:៤០- ១០:៣០ ព្រឹក |
| ២.៥ | សំណួរ ការពិភាក្សា យោបល់ និងការឆ្លើយតបរាល់អនុសាសន៍ និងសំណួរទាំងអស់ត្រូវបានកត់ត្រាក្នុងរបាយការណ៍។ | ១០:៣០- ១២:០៥ |
| ២.៦ | ធ្វើការបូកសរុបអង្គប្រជុំ និងបិទកម្មវិធីដោយប្រធានអង្គប្រជុំ | ១២:០៥-១២:១៥ |

តារាង ៨.៣.២-២: ទីកន្លែងប្រជុំ ពេលវេលាប្រជុំ និងអ្នកចូលរួមប្រជុំពិគ្រោះយោបល់ជាសាធារណៈលើទី២ ។

| ថ្ងៃ ខែ ឆ្នាំ | ទីតាំង | | | ចំនួនអ្នកចូលរួម | | | |
|---|---|---|---|---|---|---|---|
| | ខេត្ត | ក្រុង | កន្លែងប្រជុំ | មកពីភ្នាក់ងាររដ្ឋ | ពីសហគមន៍ | អង្គការក្រៅ | វិស័យឯកជន |
| ០៣/០២/០៩ | កោះកុង | ខេមរភូមិន្ទ | សាលាខេត្ត | ១៧ | ១៥ | ៤ | ១ |
| | | | សរុប: | ៣៧នាក់ | | | |

<u>**សំគាល់:**</u> ក្រុមសិក្សាមានគ្នា ៦នាក់ និងម្ចាស់គំរោងមាន ១នាក់ ។

អង្គប្រជុំបានបង្ហាញពីលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពនៃវារីអគ្គិសនីស្ទឹងតាតៃ ព្រមទាំងបង្ហាញពីប្លង់វិស្វកម្ម និងទិដ្ឋភាពបរិស្ថានគឺត្រូវបានផ្សព្វផ្សាយបង្ហាញជូនយ៉ាងច្បាស់ដោយមានឧបករណ៍ជំនួយដូចជា (កម្មវិធីជំនួយក្នុងផ្នែកកំព្យូទ័រ powerpoint, words/excels, និង មានរូបភាពផែនទី) ធ្វើការប៉ាន់ប្រមាណទៅលើហេតុប៉ះពាល់របស់គំរោងក្នុងដំណាក់ការសាងសង់ និងប្រតិបត្តិការរបស់គំរោង រៀបចំវិធានការកាត់បន្ថយទុកជាមុនសំរាប់ផលប៉ះពាល់ជាអវិជ្ជមាននីមួយៗ។ សំណួរ ការពិភាក្សា និងយោបល់ផ្សេងៗ គឺអនុលោមទៅតាមដំណាក់ការនៃការបង្ហាញនីមួយៗ។ រាល់អនុសាសន៍ទាំងអស់ និងសំណួរត្រូវបានកត់ត្រាទុកដោយក្រុមសិក្សាហើយសំណើ និងសំណួរមួយចំនួនធំត្រូវបានឆ្លើយតបភ្លាមៗ។ លទ្ធផលនៃអង្គប្រជុំបានរៀបរាប់នៅក្នុងតារាង ៨.៣.២-៣ ដូចខាងក្រោម ។

Draft

តារាង ៨.៣.២-៣: លទ្ធផលនៃអង្គប្រជុំជាមួយអ្នកដែលពាក់ព័ន្ធលើកទី២ ។

| **ឈ្មោះអ្នកចូលរួម** | **មុខរបរ និងទីកន្លែង** | **គំនិត អនុសាសន៍ និងសំនួរ** |
|---|---|---|
| លោក ជុំ យូហៀន | តំណាងអភិបាលខេត្តកោះកុង | តាងនាមឱ្យអភិបាលខេត្តកោះកុងខ្ញុំសប្បាយរីករាយយ៉ាងខ្លាំងចំពោះការចូលរួមប្រជុំជាលើកទី២ស្តីអំពីការអភិវឌ្ឍគំរោងវារីអគ្គិសនីតាតៃនេះ។ ខ្ញុំនៅចាំបានថា បន្ទាប់ពីការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា សំរាប់ការសិក្សាសមិទ្ធិលទ្ធភាព រវាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និងក្រុមហ៊ុនគ្រឿងចក្រធនធ្ងន់ជាតិចិន (CHMC) កាលពីខែមករា ឆ្នាំ២០០៧ ហើយក្រុមហ៊ុនបានរៀបចំសិក្សាគំរោងប្លង់វិស្វកម្មនិងបរិស្ថាន។<br>ការសិក្សាអំពីសមិទ្ធិលទ្ធភាពនេះបានបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០០៧ និងរបាយការណ៍ IEE ត្រូវបានយល់ព្រមពីក្រសួង បរិស្ថានក្នុងខែមីនា ឆ្នាំ២០០៨។ ក្នុងពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាមានការខ្វះខាតភ្លើងក្នុងការប្រើប្រាស់ទាំងក្នុងគ្រួសារ សហគ្រាស និងឧស្សាហកម្មផងដែរ។ ជាងនេះទៅទៀតតំរូវការថាមពលកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុង |

| | | |
|---|---|---|
| | | ពេលដែលការផ្គត់ផ្គង់ភ្លើងមានតិចតួច ហើយតម្លៃភ្លើងនេះទៀតសោតថ្លៃជាងប្រទេសជិតខាង។ ពិតមែនហើយ ខេត្តកោះកុងបាននាំចូលថាមពលអគ្គិសនី៦មេហ្គាវ៉ាត់ ក្នុងពេលថ្មីៗនេះនឹងត្រូវបង្កើនទៅដល់ ១៥មេហ្គាវ៉ាត ក្នុងឆ្នាំ ២០១៥ ខាងមុខនេះ។<br>ដោយផ្អែកទៅលើផែនការមេក្នុងការអភិវឌ្ឍវិស័យថាមពលរបស់រាជរដ្ឋាភិបាលឆ្នាំ២០០៦ គឺទីកន្លែងសំខាន់១១៣ សំរាប់ការអភិវឌ្ឍវារីអគ្គិសនីត្រូវបានគេជ្រើសរើសជាអាទិភាពសំរាប់ការអភិវឌ្ឍថាមពលអគ្គិសនីចាប់ពីឆ្នាំ២០០៧ ដល់ ២០២២។ គំរោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងតាតៃ គឺជាវារីអគ្គិសនីអាទិភាពមួយដែលត្រូវបានឆ្លើយតបតំរូវការថាមពលរបស់ប្រទេសក្នុងឆ្នាំ ២០០៧-២០២០។ អ្វីដែលខ្ញុំយល់នោះគឺថា គំរោងអាចឈានទៅដល់ការអនុវត្តបានលុះត្រាតែធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយ គោរពទៅតាមច្បាប់នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការត្រួតពិនិត្យពីក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមុននឹងបញ្ជូនរបាយការណ៍នេះទៅរាជរដ្ឋាភិបាល ដើម្បីធ្វើការសំរេចចិត្ត។ អាស្រ័យដូចនេះហើយ ការប្រជុំនៅថ្ងៃនេះគឺវាមានសារៈសំខាន់ណាស់សំរាប់អ្នកចូលរួមទាំងអស់ដើម្បី ផ្តល់ជាគំនិតយោបល់ និងបទពិសោធន៍ល្អៗ និងចូលរួមចំណែកទាំងការសិក្សាប្លង់វិស្វកម្ម និងការសិក្សាពីបរិស្ថានក្នុងតំបន់គំរោងទាំងមូល។<br>ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការប្រជុំបានប្រព្រឹត្តទៅយ៉ាងរលូន និងបានទទួលលទ្ធផលល្អជាទីមោទនៈ។ |
| លោក ផន ឡាយវិរៈ | ប្រធានមន្ទីរកសិកម្ម ខេត្តកោះកុង | ស្នើទៅវិស្វករក្រុមហ៊ុន CHMC/CTHL-NWH ឱ្យធ្វើការសិក្សាសង្ខេបប្លង់វិស្វកម្មឱ្យបានច្បាស់លាស់ ដោយធ្វើការជ្រើសរើសជំរើសគ្រប់សមាស ធាតុរបស់គំរោងទាំងអស់។ |
| លោក សេង គីមឫទ្ធី | តំណាងឱ្យក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | គាត់បានបញ្ជាក់ថាក្នុងពេលបច្ចុប្បន្ននេះគំរោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងតាតៃដែលមានតម្លៃសរុប៥៤០លានដុល្លាអាមេរិក នឹងលក់ថាមពលអគ្គិសនីទៅឱ្យអគ្គិសនីកម្ពុជាក្នុងតម្លៃ 0.0៧ដុល្លាអាមេរិក ក្នុង ១គីឡូវ៉ាត់ម៉ោង ប្រសិនបើមានការសិក្សាដទៃទៀតរួមទាំងការសិក្សាផ្នែកបរិស្ថាន នោះនឹងអាចកើនតម្លៃសំរាប់ការបន្ថែមទូទាត់ទៅលើថវិកាវិនិយោគគំរោងជាងមុន។ ហើយតម្លៃលក់ថាមពលអគ្គិសនីទៅឱ្យអគ្គិសនីកម្ពុជានឹងឡើងខ្ពស់ជាងនេះ ហើយអគ្គិសនីកម្ពុជាក៏មិនអាច |

Draft

| | | |
|---|---|---|
| | | ទិញភ្លើងនេះបានដែរ ។ |
| លោកស្រី ស៊ូវ៉ាន់ណា ហ្គាន់លែត | នាយកប្រចាំប្រទេស នៃអង្គការ Wildlife Alliance | គាត់បានស្នើបីចំណុចទៅក្រុមហ៊ុនចិន និងមន្ត្រីសាលាខេត្តហើយ នឹងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលទាំងអស់គឺ:<br>១-ចង់ពិភាក្សាទៅលើសេដ្ឋកិច្ចនៃទីជំរាល<br>២-ចង់ពិភាក្សាអំពីការប៉ះពាល់<br>៣-សំណើទាំងឡាយ<br>ស្ទឹងតាតៃមានតម្លៃ៣ដូចជា:<br>- តំបន់ព្រៃទីជំរាលទឹកមានទំហំ ៨៨០០០ហ.ត ដែលផ្តល់ជាប្រភពទឹកទៅឱ្យតំបន់ខាងក្រោម។ ប្រសិនបើគ្មានព្រៃអញ្ចឹងគឺគ្មានទឹកហូរចូលមកក្នុងស្ទឹងតាតៃទៀតទេ ហើយចុងក្រោយគឺគ្មានទឹកសំរាប់ធ្វើវារីអគ្គិសនីផងដែរ ។ ដូច្នេះតំបន់ទីជំរាលទឹកនិងព្រៃនៅទីនោះគឺ មានតម្លៃសេដ្ឋកិច្ចរួចជាស្រេច ។ អាស្រ័យហេតុនេះយើងត្រូវការពារព្រៃគ្រប់ប្រភេទទាំងអស់ដើម្បីផ្តល់ទឹកធ្វើទំនប់វារីអគ្គិសនីអាចប្រតិបត្តិការបាន ។ ព្រៃឈើវាបានផ្តល់ឱ្យជាតម្លៃ សេដ្ឋកិច្ចទៅគ្រប់ភ្នាក់ងារដែលពាក់ព័ន្ធទាំងអស់ ។<br>- ព្រៃឈើនៅក្នុងទីជំរាលទឹក និងនៅក្នុងតំបន់នឹងផ្តល់ឱ្យវិស័យសេដ្ឋកិច្ចដើម្បីស្រូបយកឧស្ម័នកាបូនិចដែលពួកបស្ចិមប្រទេសអាចទិញជា ឥនទានកាបូន ដែលអាចផ្តល់ប្រាក់ចំណូលដល់រាជរដ្ឋាភិបាលនិងប្រជាជនក្នុងតំបន់ ។ ដូច្នេះអាងស្តុកទឹកទាំង៤នៃគំរោងវារីអគ្គិសនីនៅក្នុងតំបន់នឹងផ្តល់ភាពងាយរងគ្រោះប្រសិនបើពួកបស្ចិមប្រទេសមិនទិញជាឥនទានកាបូននោះទេ ដែលនាំឱ្យមានការថយចុះប្រាក់ចំណូលក្នុងតំបន់ និងចំណូលជាតិផងដែរ ។ ហេតុអ្វីបានជាមានភាពគ្រោះថ្នាក់ទៅលើការលក់ឥនទានកាបូន? ពីព្រោះអាងស្តុកទឹកនឹងបញ្ចេញឧស្ម័នពុលដូចជា មេតានបានពីការពុកផុយនៃកំទេចកំទីរុក្ខជាតិបន្ទាប់មករំខានទៅដល់សមត្ថភាពស្រូបយកកាបូននៃដើមឈើទាំងឡាយ ។ យើងស្នើសុំទៅក្រុមហ៊ុនចិន (ក្រុមហ៊ុនអនុវត្តគំរោង) គួរកាប់ដើមឈើគ្រប់ប្រភេទទាំងអស់នៅក្នុងតំបន់អាងស្តុកទឹក ជាជាងកាប់តែដើមឈើប្រណិត១ប៉ុណ្ណោះនៅក្នុងនិងក្រៅតំបន់អាងស្តុកទឹក ដែលបានកើតមានឡើងក្នុងគំរោងអាតៃរួចទៅហើយ ។<br>- តម្លៃនៃវិស័យទេសចរណ៍គឺវាអាស្រ័យទៅនឹងភាពសម្បូរបែបនៃធនធានបរិស្ថានដូចជាព្រៃឈើ សត្វព្រៃ និងសោភ័ណភាពធម្មជាតិ |

| | | |
|---|---|---|
| | | ឧទាហរណ៍ ស្វាតព្រៃជាង៥០ប្រភេទរួមទាំងដីរ ដែលបានផ្តល់សក្តានុពលដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ យើងស្នើសុំទៅក្រុមហ៊ុនរចនាប្លង់គំរោងដើម្បីផ្លាស់ប្តូរអាគារផលិតថាមពល ទៅទីតាំងទឹកធ្លាក់ខាងលើបើអាចធ្វើទៅបាន។ និយាយអំពីផលប៉ះពាល់ក្រុមហ៊ុននឹងនាំកម្មករចំនួន៤១០០នាក់ ក្នុងអំឡុងពេលការសាងសង់គំរោង ដូច្នេះកាកសំណល់ចេញពីមនុស្សប្រចាំថ្ងៃគឺ ៥តោនក្នុង១ថ្ងៃ ឬក៏១៥០តោនក្នុង១ខែ។ ស្នើឱ្យក្រុមហ៊ុនមានវិធានការកាត់បន្ថយសមហេតុផលដូចជាការផ្តល់ប្រព័ន្ធអនាម័យដ៏ត្រឹមត្រូវនិងសមរម្យ។ ក្រុមហ៊ុនត្រូវតែបោះជំរុំកម្មករដោយរកទីកន្លែងឱ្យបានត្រឹមត្រូវ និងមិនអនុញ្ញាតិឱ្យកម្មករបោះជំរុំពង្រើកទីតាំងដោយខ្លួនឯងឡើយ។ ខ្ញុំបានធ្វើការពិភាក្សារួចហើយជាមួយលោកតាំង សុផាន់ណារ៉ា ដែលថាជំរុំកម្មករគួរត្រូវបានសាងសង់ក្នុងតំបន់ដែលបានស្នើសុំមានផ្ទៃដី ៩៤ហ.ត ហើយជំរុំកម្មករទាំងអស់រុះរើចេញ ដោយដាំជំនួសវិញនូវដើមឈើ។ ចំណុចចុងក្រោយខ្ញុំបានរកឃើញថាការបង្ហាញរបស់ក្រុមសិក្សាគឺមានតម្លាភាពនៃការខូចខាតទៅលើតំបន់ព្រៃឈើ ដោយសកម្មភាពគំរោងគឺ ៣១២០ហ.ត ប៉ុន្តែខ្ញុំគិតថាព្រៃឈើ បាត់បង់ដោយសារគំរោងប្រហែលជាតិចជាងតួលេខនេះ បើយោងទៅតាមកន្លែងខ្លះនឹងត្រូវបានដាំដើមឈើឡើងវិញបន្ទាប់ពីការបញ្ចប់សកម្មភាពសាងសង់។ ព្រៃឈើដែលត្រូវបានគេកាប់នោះគឺ ២៥៩៦ហ.ត តែប៉ុណ្ណោះ (ដោយអង្គការ Wildlife Alliance) ដូច្នេះយើងបានស្នើសុំទៅរាជរដ្ឋាភិបាលថា ចំពោះព្រៃឈើនេះត្រូវទទួលខុសត្រូវដោយរដ្ឋបាលព្រៃឈើនៃក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដែលការកាប់ឈើត្រូវបានគេធ្វើនៅក្នុងតំបន់គំរូវការ ដូចជានៅក្នុងអាងស្តុកទឹក ក្នុងជំរុំបុគ្គលិកកម្មករ និងនៅតាមបណ្តោយនៃខ្សែបញ្ជូនចរន្តអគ្គិសនី។<br>សំណើយ៉ាងទទូចនោះថាសូមឱ្យមានការគ្រប់គ្រងយ៉ាងតឹងរឹងពីរដ្ឋបាលព្រៃឈើក្នុងការប្រតិបត្តិការល្អជាមួយ Wildlife Alliance និងក្រុមហ៊ុនអនុវត្តន៍គំរោង។ |
| លោកស្រី<br>ចេននេត ញូមែន | ម្ចាស់ផ្ទះសំណាក់ឥន្ទធនូតាតៃក្រោម<br>(Rainbow Lodge in Tatay Kroam) | ជាបឋមខ្ញុំសូមថ្លែងអំណរគុណដល់អង្គប្រជុំនៅថ្ងៃនេះដែលបានអនុញ្ញាតិខ្ញុំឱ្យចូលរួមគំនិតស្តីអំពីគំរោងវារីអគ្គិសនីនេះ ហើយខ្ញុំបានយល់ព្រមទាំងស្រុងនូវវិធានការកាត់បន្ថយទៅលើហេតុប៉ះពាល់ដែលបានលើកឡើងដោយក្រុមសិក្សាស្រាវជ្រាវ។ អ្វីដែលខ្ញុំចង់ពិភាក្សានោះ |

Draft

| | | |
|---|---|---|
| | | គឺ ផ្តោតទៅលើទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ដូចជា កន្លែងទឹកធ្លាក់ ព្រៃឈើជាដើម ។ល ។ ដែលវាបានធ្វើឱ្យមានចំណាប់អារម្មណ៍ដល់ភ្ញៀវទេសចរណ៍បរទេស ហើយខ្ញុំបានទាក់ទងតាមរយៈបាងកកអ៊ែរវេ និងឆាយណាអ៊ែរវេ សំរាប់ការថតរូបភាពនៅទីនេះ។ នៅក្នុងខែឧសភាមុននេះអ្នកកាសែតសាំងកាពូថែមបានថតទេសភាពនៅទីនេះដែរ ដោយសារព័តិមានទាំងអស់នោះខ្ញុំបានទទួលភ្ញៀវបរទេស២០០នាក់ក្នុង១ឆ្នាំ ទោះបីជាកិច្ចការជំនួញរបស់ខ្ញុំវាតូចក៏ដោយ (ផ្ទះសំណាក់ និងអ្នកនាំភ្ញៀវ)។ ភ្ញៀវទេសចរណ៍បានស្នាក់នៅក្នុងផ្ទះសំណាក់រ៉េនបូពូក គេបានទស្សនាក្រុងកោះកុង ព្រៃកោងកាងនៅក្នុងបឹងប៉ាយាក់ ព្រៃភ្នំថ្មបាំង និង ជីផាត។ អាស្រ័យហេតុនេះស្នើឱ្យសាងសង់អាគារផលិតថាមពលអគ្គិសនីនៅក្នុងទីតាំងដែលមិនប៉ះពាល់ទៅដល់តំបន់ទឹកធ្លាក់ និង គុណភាពទឹក ។ ទោះបីយ៉ាងណាក៏ដោយខ្ញុំសូមកោតសរសើរទៅដល់ក្រុមសិក្សាគំរោង និងក្រុមហ៊ុនព្យាយាមធ្វើយ៉ាងណាឱ្យការប៉ះពាល់នូវកំរិតទាបបំផុតពីការជ្រើសរើសការដ្ឋានគំរោង។ ការព្រួយបារម្ភចុងក្រោយរបស់ខ្ញុំនោះ គឺការបញ្ចេញទឹកពីរោងចក្រអគ្គិសនី១៥០ម៣ក្នុង១វិនាទីប្រហែលការបង្ហូរមួយដ៏ធំ ដែលអាចធ្វើឱ្យគ្រោះថ្នាក់ដល់ភ្ញៀវទេសចរណ៍ដែលជិះទូកនៅខ្សែទឹកខាងក្រោម(រោងចក្រអគ្គិសនីនេះ)។<br>សំណើឱ្យក្រុមហ៊ុន គួរពិចារណាឱ្យបានត្រឹមត្រូវទៅទីតាំងខាងលើ:<br>- តើអាចផ្លាស់ប្តូរអាគារផលិតថាមពលអគ្គិសនីទៅខាងលើជិតទីតាំងទំនប់បានដែរ ឬទេ?<br>- តើរបៀបផ្តល់ព័តិមានពីកម្មវិធីសំរាប់ការបញ្ចេញទឹកពីរោងចក្រអគ្គិសនីដើម្បីជៀសវាងគ្រោះថ្នាក់ធ្វើយ៉ាងដូចម្តេចខ្លះ? |
| លោក ដាញ់ សេរី | អនុប្រធាននាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន | ជាបឋមខ្ញុំចង់ឱ្យអ្នកចូលរួមផ្តល់ជាគំនិត យោបល់ និង អនុសាសន៍ និងការឆ្លើយតបទៅនឹងសំណួរនឹងបានផ្តល់ជូននៅពេលក្រោយ ។<br>ខ្ញុំបានដឹងថាក្រុមហ៊ុនមិនទាន់បញ្ជាក់ពីប្រាក់ទាយជូទានបរិស្ថាន សំរាប់គំរូវការការពារនិងថាតើមានតម្លៃប៉ុន្មាន? ទាក់ទងទៅនឹងបញ្ហានេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងតំណាងឱ្យ អង្គការអន្តរជាតិបានលើកឡើង: តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលបានបញ្ជាក់ថា ប្រសិនបើតម្លៃវិនិយោគកើនឡើងជាង៥៤០លានដុល្លាបន្ទាប់មកតម្លៃលក់ភ្លើងអគ្គិសនីក៏ឡើងថ្លៃផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រសួងបរិស្ថាន អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធ |

| | | |
|---|---|---|
| | | ផ្សេងទៀតមិនត្រូវមើលរំលង អំពីការការពារបរិស្ថានឡើយ ដូច្នេះស្នើឱ្យក្រុមសិក្សាពីមូលនិធិ ការការពារបរិស្ថានឱ្យបានជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលអង្គការអន្តរជាតិបានលើកឡើងត្រឹមត្រូវផងដែរគឺថា ក្រសួងបរិស្ថានចង់ឱ្យក្រុមហ៊ុនសិក្សាបន្ថែមទៅលើហេតុប៉ះពាល់ដោយធ្វើការវិភាគប្រាក់ចំណេញ។ ការវិភាគប្រាក់ចំណេញទៅលើតម្លៃនៃហេតុប៉ះពាល់បរិស្ថាន និងតម្លៃនៃផលប្រយោជន៍អាចត្រូវបានគេសិក្សាលើតម្លៃប្រើប្រាស់ និងតម្លៃមិនប្រើប្រាស់ដោយផ្ទាល់ និងដោយប្រយោល និងតម្លៃជំរើសផងដែរ។ ការធ្វើបែបនេះអាចត្រូវបានឆ្លើយតបទៅនឹងអ្វីដែលអង្គការអន្តរជាតិបានលើកឡើងនៅក្នុងអង្គប្រជុំនេះ។ ក្នុងពេលបច្ចុប្បន្ននេះក្រុមហ៊ុនបន្តធ្វើការសិក្សា ដូចនេះខ្ញុំសំណូមពរឱ្យក្រុមសិក្សា សិក្សារួមទាំងការវិភាគប្រាក់ចំណេញ ក្នុងការសិក្សាគំរោងផងដែរ។ នៅពេលបានបញ្ចប់ការសិក្សានឹងបញ្ជូនរបាយការណ៍ទាំងអស់នេះទៅក្រសួងបរិស្ថានដើម្បីពិនិត្យនិងផ្តល់ជាយោបល់ក្នុងកិច្ចសហប្រតិបត្តការជាមួយក្រសួងដែលពាក់ព័ន្ធ ដើម្បីជៀសវាងការសិក្សាឡើងវិញនឹងនាំឱ្យខាតពេលវេលា។ ការឡើងបង្ហាញបានបង្ហាញពីលទ្ធផលនៃការវិភាគគុណភាពទឹក ប៉ុន្តែសំរាប់គុណភាពខ្យល់គ្រាន់តែនិយាយជាពាក្យថាល្អដោយពុំមានលទ្ធផលនៃការវិភាគ។<br>សំណូមពរសូមឱ្យក្រុមសិក្សាធ្វើការវិភាគគុណភាពខ្យល់ដោយវាស់លក្ខខណ្ឌដែលមានស្រាប់មុន ពេលគំរោងបានអនុវត្តន៍។ ម្យ៉ាងវិញទៀតប្រសិនបើក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានរកឃើញថាតំបន់នោះមានសក្តានុពលខាងរ៉ែជាងការវិនិយោគវារីអគ្គសនី តើធ្វើដូចម្តេច? |
| លោក មាស ស៊ីថា | អនុប្រធានខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកោះកុង | សំណើឱ្យក្រុមហ៊ុនសាងសង់ផ្លូវ និងកាប់ព្រៃឈើត្រូវធ្វើការទាក់ទងផ្នែករដ្ឋបាលព្រៃឈើដើម្បីធ្វើការវាយតម្លៃ ពីព្រោះកាលពីមុនគំរោងវារីអគ្គិសនីអាតៃគេប្រើប្រាស់ព្រៃឈើមានតម្លៃមួយចំនួនប៉ុណ្ណោះ ប៉ុន្តែព្រៃឈើគ្មានតម្លៃពួកគេបានដកចេញ។ ការរិតត្បិតគឺមិនអាចគ្រប់គ្រងក្នុងការកាប់ព្រៃឈើបានទេពួកគេ បានគេចពន្ធចំពោះឈើតូចៗ។ |
| លោក អេង ប៉ូឡូ | ណអ្នកសំរបសំរួលសហគមន៍នៃអង្គការ CI | តាងនាមឱ្យអង្គការអភិរក្សអន្តរជាតិ CI ខ្ញុំស្នើសុំឱ្យក្រុមសិក្សា EIA សិក្សាឱ្យបានច្បាស់លាស់អំពីទឹកនៅផ្នែកខាងក្រោមទំនប់ ពីព្រោះឆ្នាំទី១ និង ឆ្នាំទី២នៃប្រតិបត្តការគំរោងធ្វើឱ្យទឹកមានគុណភាពអន់។<br>- តើប្រភេទសត្វណាមួយទៅដែលអាចប៉ះពាល់?<br>- តើអ្វីទៅជាតម្លៃសេដ្ឋកិច្ច? |

Draft

| | | |
|---|---|---|
| លោកស្រី ចេននេត ញូមែន | ម្ចាស់ផ្ទះសំណាក់ឥន្ទធនូ តាតៃក្រោម | នៅក្នុងកិច្ចប្រជុំកាលពីលើកមុនក្នុងឃុំតាតៃក្រោមក្រុមហ៊ុនបាននិយាយថាបន្ទាប់ពីប្រតិបត្តគំរោងឃុំនឹងបានអគ្គិសនីប្រើប្រាស់ ប៉ុន្តែមិនច្បាស់ពីតម្លៃនោះទេ។ តើតម្លៃភ្លើងនោះមានតម្លៃប៉ុន្មានក្នុងមួយគីឡូវ៉ាត់ម៉ោង? ខ្ញុំគិតថាការផលិតថាមពលពីវារីអគ្គិសនីក្នុងតំបន់ត្រូវបានបញ្ជូនទៅស្ថានីយ៍អូរសោម ហើយមិនបានបែងចែកទៅសហគមន៍មូលដ្ឋាននោះទេ។ ខ្សែបញ្ជូនចរន្តផ្សេងទៀតនៅតាមបណ្តោយផ្លូវលេខ៤៨ទៅក្រុងកោះកុង បន្ទាប់មកទៅអូរសោមគឺវាមានតម្លៃខ្ពស់ជាងផ្លូវកាត់ ពីអាគារផលិតថាមពលអគ្គិសនីទៅអូរសោម។ សំណួរៈ តើរដ្ឋាភិបាលអាចផ្តល់តម្លៃបន្ថែមទៅក្រុមហ៊ុនបានទេ? លោកស្រីបានបន្ថែមថាវាចំឡែកណាស់ដែរថាមានកន្លែងរោងចក្រវារីអគ្គិសនី៤កន្លែងនៅក្នុងខេត្តកោះកុងប៉ុន្តែបែរជាគ្មានភ្លើងប្រើប្រាស់ពីគំរោងទាំងនោះក្នុងខេត្តកោះកុងនេះ។ |
| លោក សេង គីមឫទ្ធី | តំណាងឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ទាក់ទងទៅនឹងគន្លងខ្សែបញ្ជូនចរន្តអគ្គិសនីពីអាគារផលិតថាមពលអគ្គិសនីទៅអនុស្ថានីយ៍អូរសោមគឺធ្វើទៅតាមផែនការមេរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងនាយកដ្ឋានខ្សែបញ្ជូនចរន្តអគ្គិសនីគឺទទួលខុសត្រូវទាក់ទងទៅនឹងប្លង់គំរោងបច្ចេកទេស និងការវាយតម្លៃដោយអនុលោមទៅតាមបទដ្ឋានប្រទេសកម្ពុជា។ អនុស្ថានីយ៍អូរសោមនឹងប្រមូលផ្តុំគ្រប់ថាមពលទាំងអស់ចេញពីវារីអគ្គិសនីក្នុងតំបន់ និងបញ្ជូនទៅភ្នំពេញ និងខេត្តបាត់ដំបង។ |
| លោក ហាន់ផ័រ វេល័រ | ទីប្រឹក្សាបច្ចេកទេស. រដ្ឋបាលព្រៃឈើ | លោកបានស្នើសុំក្រុមសិក្សាឱ្យសង្ខេបដំណើរការសំរាប់ជំហ៊ាន បន្ទាប់មុនពេលការអនុវត្តគំរោងនេះ។<br>- តើត្រូវបញ្ចប់ការសិក្សានៅពេលណា?<br>- តើរបាយការណ៍ EIA ផ្ញើទៅក្រសួងបរិស្ថានដើម្បីពិនិត្យនៅពេលណា?<br>- តើរបាយការណ៍ EIA ត្រូវបានគេយល់ព្រមរយៈពេលប៉ុន្មាន? |
| លោក ដុំ យូហៀន | តំណាងអភិបាលខេត្តកោះកុង | លោកបានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ និងសូមកោតសរសើរចំពោះការចូលរួមគំនិត និងយោបល់។ លោកបានបន្ថែមថាកិច្ចប្រជុំនេះមានលក្ខណៈរស់រវើក និង ទទួលបានលទ្ធផលជាផ្លែផ្កា។ លោកបានស្នើសុំឱ្យក្រុមសិក្សាស្រាវជ្រាវត្រូវពិចារណាលើយោបល់ដ៏មានប្រយោជន៍ ពីអង្គប្រជុំ។<br>ខ្ញុំសង្ឃឹមជឿជាក់ថា រដ្ឋាភិបាលមានគំរោងការបែងចែកថាមពល |



Draft

| | | |
|---|---|---|
| | | អគ្គិសនីគ្រប់ទីប្រជុំជនទាំងអស់ សហគមន៍ និងតាមបណ្តាភូមិជាគោលដៅដើម្បីកាត់បន្ថយភាពក្រីក្រ ។ |

សំណួរមួយចំនួនត្រូវបានឆ្លើយតបដោយក្រុមសិក្សា EIA និងវិស្វករសាងសង់គំរោង ។

ចំណុចខ្លះបានបញ្ជាក់ដោយតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

សិក្សាបន្ថែមអំពីការវិភាគរកប្រាក់ចំណេញ( ការវិភាគសេដ្ឋកិច្ច) បានលើកឡើងដោយអ្នកតំណាងក្រសួងបរិស្ថាន ។

អ្នកចូលរួមទាំងអស់បានកោតសរសើរអំពីការបង្ហាញលទ្ធផលយ៉ាងច្បាស់នៃការសិក្សា និងបានឆ្លើយតបយ៉ាងច្បាស់លាស់ទៅនឹងសំណួរ ។




Draft

រូបភាព ៨.៣.២ក: សកម្មភាពនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ នៅក្នុងសាលាខេត្តកោះកុង

## ៨.៤ ការជួបប្រជុំជាមួយអ្នកដែលពាក់ព័ន្ធ

ស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួនមានៈ ផ្នែករដ្ឋាភិបាល (នាយកដ្ឋាននានា) អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផ្តល់ជាយោបល់ និងកិច្ចពិភាក្សានៅក្នុងអំឡុងពេលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើម្បីសិក្សាពិស្តារពីគំរោងវារីអគ្គិសនីស្ទឹងតាតៃ ។

តារាង ៨.៤-១: លទ្ធផលនៃកិច្ចពិភាក្សា

| ថ្ងៃ ខែ ឆ្នាំ | ឈ្មោះ | តួនាទី ស្ថាប័ន | គំនិត យោបល់ និងសំណួរ |
|---|---|---|---|
| ០៤ កុម្ភៈ ០៩ | លោក សេង ប៊ុនរ៉ា | នាយកប្រចាំប្រទេស អង្គការអភិរក្សអន្តរជាតិ (CI) | - ក្នុងឆ្នាំ២០០៧ ក្រុមសិក្សាពីការត្រួតពិនិត្យហេតុប៉ះពាល់បរិស្ថានដំបូង IEE បានជួបពិគ្រោះយោបល់ជាមួយនឹងយើងអំពីព្រំដែននៃតំបន់ការពារ ព័ត៌មានពីសត្វព្រៃ និងកម្មវិធីអភិរក្សដែល CI បានចាត់ចែង និងអនុវត្តនៅក្នុងតំបន់នេះ ។ CI បានផ្តល់ព័ត៌មាន និងយោបល់មួយចំនួនស្តីអំពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងការសិក្សាសមិទ្ធិលទ្ធភាពនៃគំរោង ។<br>- ក្នុងពេលបច្ចុប្បន្ននេះ CI បានបន្តអនុវត្តការស្រាវជ្រាវសត្វព្រៃដូចជាសត្វខ្លាឃ្មុំ និងសត្វពង្រូល (នៅក្នុងតំបន់តាតៃលើ) និង ត្រីនាគ (នៅផ្នែកខាងក្រោមជិតតំបន់អគារផលិតថាមពល) ។ អ្នកស្រាវជ្រាវនៃអង្គការអភិរក្សអន្តរជាតិបានជួបប្រទះក្រុមដំរីមួយក្រុមដែលមានចំនួនពី ៧ ទៅ ១០ក្បាលដែលរស់នៅក្នុងតំបន់អភិរក្ស ។<br>- បើយោងទៅតាមគំរោងផែនការបានបង្ហាញថាទីតាំងអាងស្តុកទឹកដែលស្ថិតនៅខាងក្រៅតំបន់អភិរក្សព្រៃឈើ និងជីវចំរុះនៃជួរភ្នំកាដាម៉ុមកណ្តាល នៅឆ្ងាយពីសហគមន៍ និងឆ្ងាយពីផ្លូវ បំលាស់ទីរបស់សត្វដំរីនៅក្នុងតំបន់ ។ ដូច្នេះខ្ញុំសង្ឃឹមថា គំរោងនឹងមិនប៉ះពាល់ធ្ងន់ធ្ងរទេទៅលើសត្វព្រៃ ព្រមទាំងប្រជាជនក្នុងតំបន់ហើយក៏មិនទន្ទ្រានរំលោភចូលទៅក្នុងព្រៃសំរាប់ការតាំងទីលំនៅ ។<br>- គំរោងនឹងផ្តល់ផលប៉ះពាល់ជាអវិជ្ជមានតិចតួចទៅលើធនធានធម្មជាតិ និងនៅក្នុងកម្មវិធី និងតំបន់អភិរក្សបើ |

| | | | |
|---|---|---|---|
| | | | ប្រៀបធៀបទៅនឹងគំរោងវារីអគ្គិសនីជាយអារ៉ែង ។ ក្នុងខណៈដែលតំរូវការអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល តាងនាមឱ្យអង្គការអភិរក្សអន្តរជាតិ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រគំរោងវារីអគ្គិសនីស្ទឹងតាតៃ និងចង់ឱ្យតម្លៃភ្លើង ចុះថោកដើម្បីកាត់បន្ថយភាពក្រីក្រទៅដល់ប្រជាជន ។<br>- លោកបានផ្តល់អនុសាសន៍ថា ទោះបីជាយ៉ាងណាក៏ដោយក្រុមសិក្សាគួរតែមានទំនាក់ទំនងជាមួយនឹង WildAid ដើម្បីពិគ្រោះយោបល់អំពីហេតុប៉ះពាល់ទៅនឹងព្រៃឈើ និងជីវកសត្វព្រៃដែលបណ្តាលមកពីគំរោង ព្រោះទីតាំងគំរោងស្ថិតនៅក្នុងតំបន់អភិរក្សរបស់ WildAid ។ |
| ១៧ កុម្ភៈ ០៩ | Ms. Suwanna Gauntlett | Country Director, Wildlife Alliance/ WildAid | - អ្នកស្រីចង់ដឹងឱ្យបានច្បាស់ពីផ្លូវចូលទៅអគារផលិតថាមពល និងទីតាំងទំនប់ និងគន្លងខ្សែបញ្ជូនចរន្តពីអគារផលិតថាមពលទៅអនុស្ថានីយ៍អូរសោម ។<br>- អ្នកស្រីបានស្នើសុំក្រុមហ៊ុនរចនាប្លង់គំរោងឱ្យកាត់បន្ថយនូវទំហំអាងស្តុកទឹក ប្រវែងផ្លូវចូល និងគន្លងខ្សែបញ្ជូនចរន្តគួរធ្វើទៅតាមផ្លូវដែលមានស្រាប់នៅក្នុងតំបន់។ ជាងនេះទៅទៀតអាចកាត់បន្ថយការប៉ះពាល់ព្រៃឈើ តំបន់ការពារ ជីវកសត្វព្រៃ និងជីវិតសត្វព្រៃ ។<br>- អ្នកស្រីបានសួរសំណួរទៅដល់ក្រុមសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬក្រុមហ៊ុនសាងសង់ឱ្យផ្តល់ការសំរបសំរួលលើសមាសភាពគំរោងរួមមាន អាងស្តុកទឹក អគារផលិតថាមពល ទំនប់ និងសមាសភាពបន្ទាប់បន្សំផ្សេងៗទៀត ។<br>- WildAid អាចផ្តល់ព័តិមានមួយចំនួនទាក់ទងទៅនឹងផែនទីព្រំដែនអភិរក្ស និងផ្តល់ការសន្យាដើម្បីគាំទ្រទាំងកំលាំងកាយ និងថវិកាដើម្បីសិក្សាស្រាវជ្រាវទៅលើសត្វព្រៃនៅក្នុងតំបន់អាងស្តុកទឹក និងទីតាំងអគារផលិតថាមពលដើម្បីសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ |
| ២៣ កុម្ភៈ ០៩ | លោក អ៊ឹង ទ្រី | នាយករងរដ្ឋបាលជលផល | - គាត់មានការព្រួយបារម្ភថាគំរោងនឹងធ្វើឱ្យប៉ះពាល់ដល់ធនធានជលផលនៅក្នុងស្ទឹងតាតៃ និងស្ទឹងកែប មកពីការ |

| | | | |
|---|---|---|---|
| | | នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សាងសង់ទំនប់ ហើយនឹងកាត់ផ្តាច់ចលនាបំលាស់ទីរបស់ត្រី និងជីវចំរុះផ្សេងៗទៀតដែលរស់នៅក្នុងទឹក ។<br>- ការសិក្សាពីធនធានជលផលទាំងជីវសាស្ត្រ និងអេកូឡូស៊ីនៃស្ទឹងទាំងឡាយក្នុងតំបន់គំរោងគួរត្រូវបានអនុវត្តន៍ឱ្យបានត្រឹមត្រូវ ។ លោកបានផ្តល់ជាយោបល់ថាការប៉ាន់ប្រមាណក្នុងការចាប់ត្រីអាចត្រូវបានគេប្រើប្រាស់ទិន្នន័យអង្កេត និងទិន្នន័យដែលមានស្រាប់ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ប្រមាណផលត្រីអាចត្រូវបានគេប្រើប្រាស់ទិន្នន័យអង្កេតជាក់ស្តែង ។<br>- លោក ទ្រី បានផ្តល់អនុសាសន៍ថាការអភិវឌ្ឍក្នុងការចិញ្ចឹមត្រីនៅក្នុងតំបន់ត្រូវបានគេពិចារណាប្រសិនបើគំរោងឈានទៅដល់ការអនុវត្តនោះ ។ មជ្ឈមណ្ឌលស្រាវជ្រាវត្រីត្រូវបានបង្កើតផងដែរ ការបង្កាត់ពូជត្រីដូចជាប្រភេទត្រីដែលមានស្រាប់ ហើយបានបំរើទៅឱ្យតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ។<br>- ជាទូទៅគាត់បានស្វាគមន៍គំរោងវារីអគ្គិសនីស្ទឹងតាតៃពីព្រោះវាបានផលិតថាមពលអគ្គិសនីច្រើនដែលអាចឆ្លើយតបទៅនឹងតំរូវការថាមពលអគ្គិសនីនៅក្នុងរបទេស ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានស្នើសុំទៅក្រុមសិក្សាគំរោង ធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ឱ្យបានសមស្របដែលបណ្តាលមកពីសកម្មភាពនៃគំរោងទៅលើធនធានធម្មជាតិ ដូចជា ព្រៃឈើ ត្រី និងសត្វព្រៃ និងបង្កើតវិធានការកាត់បន្ថយឱ្យបានច្បាស់លាស់ដើម្បីកាត់បន្ថយហេតុប៉ះពាល់ អវិជ្ជមានឱ្យបានច្រើនដែលអាចធ្វើទៅបាន ។ |
| ២៤ កុម្ភៈ ០៩ | លោក ផន ឡាយវីរៈ | ប្រធានមន្ទីរកសិកម្ម ខេត្តកោះកុង | - ពុំមានសកម្មភាពកសិកម្ម ឬក៏គំរោងអភិវឌ្ឍន៏ក្នុងតំបន់គំរោងនេះទេមកដល់ខែ មីនា ឆ្នាំ ២០០៩ ។ ទោះជាយ៉ាងណាក៏ដោយការសាងសង់ និងការប្រតិបត្តិគំរោងអាចមានការប៉ះពាល់ទៅដល់គ្រួសារនេសាទត្រីនៅក្នុងភូមិដូងឃុំតាតៃក្រោម ។ ការនេសាទត្រីនៅក្នុងភូមិដូង គឺបានអនុវត្តទៅតាមរដូវកាលមិនមែនជាអចិន្ត្រៃយ៍ទេហើយមាន២-៣គ្រួសារប៉ុណ្ណោះ ។ ប្រភេទ Cab and Spong specie (*Psammoperca waigiensis*) គឺត្រូវបានគេចិញ្ចឹមនៅទីនេះ ។ |



Draft

| | | | |
|---|---|---|---|
| | | | - សកម្មភាពនេសាទត្រី គឺជាការងារជាប្រចាំរបស់អ្នកភូមិក្នុងឃុំតាតៃក្រោម ចំណែកឯការដាំដុះឈើហូបផ្លែ និងគ្រាប់ធញ្ញជាតិគឺជាការងារបន្ទាប់បន្សំរបស់គ្រួសារនីមួយៗ។ ដំណាំឈើហូបផ្លែនៅទីនេះរួមមាន ធូរ៉េន សាវម៉ាវ ដូង ខ្នុរ ស្វាយ ។ល។ ដំណាំឈើហូបផ្លែ និងដំណាំកសិកម្មត្រូវបានគេដាំដុះនៅក្នុងឃុំតាតៃក្រោមព្រមទាំងនៅក្នុងឃុំដទៃទៀតនៅក្នុងតំបន់ខ្សែទឹកខាងក្រោមនៃទីតាំងគំរោង ដែលមិនធ្លាប់ប្រើប្រាស់ទឹកពីស្ទឹងតាតៃយកទៅស្រោចស្រពដំណាំនោះទេគឺគេពឹងពាក់តែទៅលើទឹកភ្លៀង។ ទោះជាយ៉ាងណាក៏ដោយ ការដំណាំគ្រួសារក្នុងភូមិអន្លង់វ៉ាក់ និងភូមិដូងបានប្រើប្រាស់ទឹកក្រោមដីដើម្បីស្រោចស្រពដំណាំនៅក្នុងរដូវប្រាំង។<br>- គ្មានការដាំដុះដំណាំ និងបន្លែនៅតាមតំបន់បណ្តោយមាត់ស្ទឹងទេ បើយោងទៅតាមរាងរៅជាអក្សរអ៊ុយរបស់ស្ទឹងតាតៃគឺគ្មានទីវាលសំរាប់ដាំដុះទេ និងពុំទ្ធទៅដោយទឹកប្រៃខាងលើភូមិដូងនៅក្នុងរដូវប្រាំង។<br>- លោកប្រធានមន្ទីរបានបញ្ជាក់ថាគំរោងនេះមិនត្រឹមតែផ្តល់ថាមពលអគ្គិសនីនោះទេ ថែមទាំងផ្តល់ទឹកសាបទៅសហគមន៍មូលដ្ឋានទៀតផង ហើយគាត់បានគាំទ្រគំរោងនេះឱ្យអនុវត្តក្នុងពេលឆាប់ៗ។ គាត់បានស្នើឱ្យម្ចាស់គំរោងជ្រើសរើសកម្មករក្នុងស្រុកដើម្បីធ្វើការក្នុងពេលអនុវត្តគំរោង។<br>- ម្យ៉ាងវិញទៀត គំរោងអាចប៉ះពាល់ទៅដល់ប្រភពទឹក និងធនធានត្រី។ ជាងនេះទៅទៀតលោកខ្លាចដាច់ទំនប់នៅក្នុងពេលប្រតិបត្តិការគំរោងដែលអាចធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅដល់ទ្រព្យសម្បត្តិក្នុងឃុំដែលនៅខាងក្រោមតំបន់គំរោង និងអាចសំលាប់សត្វ និងមនុស្សផងដែរ។ ជាងនេះទៅទៀតលោកបានស្នើឱ្យក្រុមហ៊ុនសិក្សាគំរោងធ្វើឱ្យប្រាកដប្រជានូវរចនាប្លង់គំរោង និងការសាងសង់ត្រូវគិតពីសុវត្ថិភាព និងគុណភាពល្អបំផុត។ |
| ២៤ កុម្ភៈ ០៩ | ជ័យ ពេជ្ររតនា | ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង | - ដោយយោងទៅនឹងផែនទីគំរោង និងព័ត៌មានគំរោងដែលបានផ្តល់ឱ្យដោយក្រុមសិក្សា KCC/CTHL បានបង្ហាញថាគំរោងមិនប៉ះពាល់ទៅនឹងតំបន់ការពារដែលរៀបចំដោយក្រសួងបរិស្ថាននៅក្នុងខេត្តកោះកុងនោះទេវាមានន័យថារាល់សមាសធាតុគំរោងទាំងអស់គឺវាស្ថិតនៅខាងក្រៅតំបន់ការពារពាមក្រសោប។ ទោះជាយ៉ាងណាក៏ |

| | | | |
|---|---|---|---|
| | | | ដោយទីតាំងគំរោងបានចូលទៅក្នុងតំបន់ការពារដែលគ្រប់គ្រងដោយអង្គការអភិរក្សអន្តរជាតិ CI និង Wildlife Alliance/Wild Aid ។ ជាងនេះទៅទៀតគំរោងនឹងអាចប៉ះពាល់ទៅដល់តំបន់សហគមន៍អេកូទេសចរណ៍.ឃុំតាតៃក្រោមក្នុងស្រុកកោះកុង ។<br>- គំរោងនឹងធ្វើឱ្យខូចខាតព្រៃឈើនៅក្នុងតំបន់ទីតាំងអាងស្តុកទឹក និងប៉ះពាល់ទៅដល់សហគមន៍នៅខ្សែទឹកខាងក្រោមមួយចំនួន ដូច្នេះសូមឱ្យម្ចាស់គំរោងដាំដើមឈើឡើងវិញនៅក្នុងតំបន់ទំនេរជិតតំបន់គំរោង និងជួយបណ្តុះបណ្តាលប្រជាជនដែលប៉ះពាល់ឱ្យគាត់ចេះអំពីវិជ្ជាជីវៈថ្មីៗដើម្បីឱ្យពួកគេអាចទ្រទ្រង់ជីវភាពរបស់ពួកគេបាន ។<br>- លោកប្រធានបានស្វាគមន៍ និងគាំទ្រគំរោងនេះទាំងស្រុង និងសន្យាសហប្រតិបត្តិការល្អជាមួយនឹងក្រុមហ៊ុនអនុវត្តន៏គំរោង ។<br>- លោកបានសំណូមពរទៅក្រុមហ៊ុនអនុវត្តគំរោងអនុញ្ញាតឱ្យបុគ្គលិកមន្ទីរបរិស្ថានខេត្តកោះកុងម្នាក់បានបំរើការងារជាដៃគូក្នុងការសាងសង់ និងប្រតិបត្តិការគំរោង ដែលជាអ្នកសហការណ៏ក្នុងការចែករំលែកព័តិមានបរិស្ថាន និងការគ្រប់គ្រង។ គាត់បានបន្ថែមថាក្រុមហ៊ុនត្រូវទទួលខុសត្រូវក្នុងការផ្តល់ប្រាក់បៀវត្សរ៍ប្រចាំខែ (ពី១៥០-២០០ដុល្លា) និងស្នាក់នៅក្នុងទីតាំង (ជំរុំ) ។<br>- ស្នើឱ្យក្រុមហ៊ុនអនុវត្តន៏គំរោងបង្កើតមជ្ឈមណ្ឌលអប់រំបរិស្ថានក្នុងតំបន់គំរោង និងផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពទៅដល់បុគ្គលិកមន្ទីរបរិស្ថាន (៣-៥នាក់) ក្នុងវិស័យបច្ចេកទេស និងការគ្រប់គ្រង ។ |
| ២៤ កុម្ភៈ ០៩ | លោក យ៉ន ទីន | អនុប្រធានមន្ទីរទេសចរណ៏ ខេត្តកោះកុង | - ក្នុងពេលបច្ចុប្បន្ននេះមន្ទីរទេសចរណ៏បាននឹងកំពុងចុះបញ្ជីសារពើភ័ណ្ឌហេដ្ឋារចនាសម្ព័ន្ធទេសចរណ៏ ដូចជាឆ្នេរខ្សាច់ប្រវែង ២៣៧គ.ម កោះ២៣កោះ ផ្ទៃដីព្រៃកោងកាងមានទំហំ ៦៣០០០ហ.ត ក្នុងនោះ៥០០០ហ.ត ក្នុងតំបន់អភិរក្សសត្វព្រៃពាមក្រសោប តំបន់ទឹកធ្លាក់ ៦កន្លែង(តាតៃក្នុងស្រុកកោះកុង កោះពោធិ ក្បាលឆាយ E91 ក្នុងស្រុកមណ្ឌលសីមា អារ៉ែង ក្នុងស្រុកថ្មបាំង តាផន និងតាវែងក្នុងក្រុងខេមរភូមិន្ទ) អូតែលចំនួន៥ |

| | | | |
|---|---|---|---|
| | | | ផ្ទះសំណាក់ ១៣ ភោជនីយដ្ឋាន១៥ សហគមន៍អេកូទេសចរណ៍ក្នុងឃុំជីផាតស្រុកថ្មបាំង ដែលបានគាំទ្រដោយអង្គការមិត្តសំឡាញ់ សហគមន៍អេកូទេសចរណ៍ក្នុងឃុំតាតៃក្រោម ស្រុកកោះកុងបានគាំទ្រ ថវិកាដោយ PSDD ។ បច្ចុប្បន្ន នេះអង្គការមិត្តសំឡាញ់បានបង្កើត សហគមន៍អេកូទេសចរណ៍ក្នុងឃុំត្រពាំងរូង ស្រុកកោះកុង។ ក្រៅពីការអះអាងខាងលើមន្ទីរទេសចរណ៍មានផែនការ ៥ឆ្នាំក្នុងគំរោងនោះដែរមជ្ឈមណ្ឌលអេកូទេសចរណ៍ក្នុងឃុំជាយអារ៉ែង ស្រុកថ្មបាំងនឹងត្រូវបានបង្កើតឡើង ។<br>- ទាក់ទងទៅនឹងគំរោងវារីអគ្គិសនីស្ទឹងតាតៃគាត់បានបញ្ជាក់ថា គំរោងនេះនឹងប៉ះពាល់ធនធានធម្មជាតិជាពិសេសការខូចខាតព្រៃឈើក្នុងទីតាំងអាងស្តុកទឹក និងធ្វើឱ្យប្រែប្រួលការប្រើប្រាស់ដីនៅក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយ គាត់សង្ឃឹមថាសមាសធាតុគំរោងនឹងផ្តល់ឱ្យខាងវិស័យទេសចរណ៍ច្រើននៅក្នុងតំបន់នេះជាពិសេសគំរោងនឹងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចជាតិច្រើនជាងតម្លៃនៃការខូចខាត ។<br>- គាត់បានស្វាគមន៍គំរោងនេះយ៉ាងកក់ក្តៅ និងសំណើឱ្យម្ចាស់គំរោងអនុវត្តដូចជា:<br>• ជួយធ្វើផ្លូវថ្មបាំងបើមានលទ្ធភាព<br>• សហប្រតិបត្តិការជាមួយមន្ទីទេសចរណ៍ខេត្តដើម្បីអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិទស្សនាគំរោងក្នុងដំណាក់ការប្រតិបត្តិការ ។ |
| ២៤ កុម្ភៈ ០៩ | លោក ប៊ិច ស៊ីយ៉ុន | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកោះកុង | - ក្នុងពេលបច្ចុប្បន្ននេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលតាមរយៈមន្ទីរបានសហប្រតិបត្តិការជាមួយក្រុមហ៊ុនលី យ៉ុងផាត់នាំចូលថាមពលអគ្គិសនីសរុប ៦មេកាវ៉ាត់ពីប្រទេសថៃតាមសេចក្តីត្រូវការក្នុងតំបន់។ តម្លៃភ្លើងអគ្គិសនីប្រើប្រាស់គឺ ៦០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោងសំរាប់អ្នកប្រើប្រាស់ទាំងអស់។ ទោះយ៉ាងណាក៏ដោយ យោងទៅលើផែនការរបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលនឹងត្រូវបានបង្កើនឡើងរហូតទៅដល់ ២៥ មេហ្គាវ៉ាត់ក្នុងឆ្នាំ ២០១៥ ខាងមុខ ។ |

Draft

| | | | |
|---|---|---|---|
| | | | - ជាការពិតនៅក្នុងខេត្តកោះកុងមានសក្តានុពលខ្ពស់នៃតំបន់អភិវឌ្ឍន៍វារីអគ្គិសនីនេះបើយោងទៅតាមធនធានធម្មជាតិ។ ទោះជាយ៉ាងណាក៏ដោយរោងចក្រវារីអគ្គិសនីគ្រាន់តែមាននៅក្នុងគំរោងផែនការ និងការសិក្សាតែប៉ុណ្ណោះ ឧទាហរណ៍ក្នុងពេលបច្ចុប្បន្ននេះមានដូចជាវារីអគ្គិសនីស្ទឹងអារ៉ែង ស្ទឹងឫស្សីជ្រុំ ស្ទឹងតាតៃ ស្ទឹងមេទឹក ។ល។<br>- គ្មានការធ្វើអាជីវកម្មរ៉ែក្នុងតំបន់គំរោងនេះទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយចំងាយពី ៧-១០គ.ម ផ្នែកខ្សែទឹកខាង ក្រោមនៃអាគារផលិតថាមពលមានការធ្វើអាជីវកម្មរ៉ែខ្សាច់ដោយក្រុមហ៊ុន លី យ៉ុងផាត់។<br>- សំណើទៅក្រុមហ៊ុនអនុវត្តន៍គំរោងធ្វើការវិភាគរ៉ែក្នុងការសិក្សាភូគព្ភសាស្ត្រសំរាប់គំរោង ប្រសិនបើរកឃើញរ៉ែមានប្រយោជន៍ផ្នែកសេដ្ឋកិច្ច អញ្ចឹងគំរោងត្រូវបានគេពិចារណាទៅលើបញ្ហានេះ។<br>- លោកបានស្នើសុំទៅម្ចាស់គំរោងឱ្យផ្តល់ការពង្រឹងសមត្ថភាពទៅដល់បុគ្គលិកមន្ទីរ ជាវគ្គបណ្តុះបណ្តាលការងារធ្វើការជាបុគ្គលិកដៃគូក្នុងការសាងសង់គំរោង (៥នាក់) និងក្នុងពេលប្រតិបត្តិការគំរោង(២នាក់) និងឧបត្ថមប្រាក់បៀវត្សរ៍ និងកន្លែងស្នាក់នៅក្នុងទីតាំងគំរោង។<br>- ស្នើឱ្យម្ចាស់គំរោងជួយសាងសង់មន្ទីរ ឬក៏សហការណ៍ជាមួយគំរោងផ្សេងទៀតបើអាចធ្វើទៅបាន។<br>- ឧបត្ថមទៅដល់បុគ្គលិកមន្ទីរ(៣-៥នាក់)ជាមួយនឹងវគ្គបណ្តុះបណ្តាលអំពីវិស័យបច្ចេកទេស និងការគ្រប់គ្រង។<br>- លោកប្រធានមន្ទីរបានគាំទ្រគំរោងនេះ១០០% និងបានសន្យាសហប្រតិបត្តិការ និងសំរបសំរួលនូវរាល់ការងារទំនាក់ទំនងទាំងអស់ជាមួយនឹងមន្ទីរ និងក្រសួងព្រមទាំងអាជ្ញាធរដែនដីដើម្បីឱ្យការអនុវត្តគំរោង ប្រព្រឹត្តទៅបានយ៉ាងរលូន។ គាត់ចង់ឱ្យគំរោងដំណើរការបានឆាប់រហ័សដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនទូទាំងខេត្ត និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ |
| ០៨ មិថុនា ០៧ | លោក ស៊ីវ សាបាន | អភិបាលស្រុករងស្រុក | - អាជ្ញាធរស្រុកថ្មបាំងបានដឹងអំពីគំរោងអភិវឌ្ឍន៍វារីអគ្គិសនីតាមរយៈទូរទស្សន៍ អភិបាលខេត្តកោះកុង និង |

| | | | |
|---|---|---|---|
| | | ថ្មបាំង | ប្រធាន គំរោង CHMC/CTHL ។ តាងនាមឱ្យអាជ្ញាធរមូលដ្ឋាន និងខ្លួនគាត់ផ្ទាល់បានស្វាគមន៍នូវគំរោងនេះ ។<br>- ស្នើសុំឱ្យម្ចាស់គំរោងផ្តល់ឱកាសទៅដល់ប្រជាជនមូលដ្ឋានធ្វើការនៅក្នុងការសាងសង់គំរោងនេះផង ។ |
| ០៨ មិថុនា ០៧ | លោក ម៉េង វ៉ា | មេឃុំឫស្សីជ្រុំ | - ប្រជាជនក្នុងឃុំឫស្សីជ្រុំបានដឹងពីគំរោងតាតៃតាមរយៈទូរទស្សន៍ និងបានឃើញក្រុមសិក្សាចិនចុះតាមទីវាល ។<br>- សំណើឱ្យក្រុមអ្នកសិក្សាគំរោងសូមធ្វើប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋានដូចជាជាមួយថ្នាក់ភូមិ និងថ្នាក់ ឃុំ ក្នុងដំណាក់ការគំរោងទាំងមូល ។<br>- ផ្តល់សំណងទូទាត់សងគ្រួសារដែលប៉ះពាល់នឹងធ្វើឱ្យបាត់បង់ដី និងទ្រព្យសម្បត្តិផ្សេងៗរបស់ពួកគេដោយសារ គំរោង ។<br>- សង្ឃឹមថាគំរោងនឹងផ្តល់ផលប្រយោជន៍ទៅដល់សហគមន៍នៅទីនេះផ្ទាល់ ។ |
| ០៨ មិថុនា ០៧ | លោកស្រី មាស សុផាន | កម្មវិធីសុខភាព អង្គការសង្គ្រោះសត្វព្រៃ កម្ពុជា (SCW) | - លោកស្រីបានស្វាគមន៍គំរោងវារីអគ្គិសនីស្ទឹងតាតៃ និងរំពឹងថាធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌជីវិតនៃប្រជាជន មូលដ្ឋានជាមួយនឹងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗដើម្បីបញ្ចៀសភាពក្រីក្រ ។<br>- ការផ្តល់ឱ្យដីថ្មីសំរាប់គ្រួសារក្រីក្រដែលបាត់បង់ដីរបស់ពួកគេត្រូវបានផ្តល់អនុសាសន៍ ពីព្រោះប្រជាជនភាគច្រើន នៅទីនេះពឹងផ្អែកទៅលើវិស័យកសិកម្ម ។ |
| ០៨ មិថុនា ០៧ | លោកស្រី សៀក ស៊ីសុខុម | អ្នកសំរបសំរួលអង្គការ CARE Cambodia | - ការទូទាត់សងត្រូវបានធ្វើជាមួយនឹងស្ថានភាពជាក់ស្តែងនូវអ្វីដែលពួកគេបានបាត់បង់ដូចជា ដី ផ្ទះសំបែង និង ការងារ ។<br>- សេវាសាធារណៈគួរត្រូវបានផ្តល់ឱ្យក្នុងការតាំងទីលំនៅថ្មីរួមទាំងសាលារៀន មណ្ឌលសុខភាព ។ល ។ |
| ០៨ មិថុនា ០៧ | លោក សាន មុន្នីរ័ត្ន | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | - លោកបានស្វាគមន៍នូវគំរោងវារីអគ្គិសនីស្ទឹងតាតៃដែលអាចផ្តល់ថាមពលអគ្គិសនីប្រើប្រាស់ដូចជាតំរូវការក្នុង ខេត្ត និងប្រទេសទាំងមូល និងកាត់បន្ថយការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង ។ |

| | | | |
|---|---|---|---|
| | | ខេត្តកោះកុង | - មានការព្រួយបារម្ភអំពីទឹកជំនន់ផ្នែកខាងលើខ្សែទឹក និងមានការខ្វះខាតទឹកនៅផ្នែកខាងក្រោមខ្សែទឹកប្រសិនបើ មានការសាងសង់វារីអគ្គិសនីនៅក្នុងតំបន់ស្ទឹងតាតៃមែននោះ ។ លោកបានស្នើសុំទៅក្រុមសិក្សាត្រូវពិចារណាអំពីបញ្ហាខាងលើ ។<br>- ការពាក់ព័ន្ធមានការសហការពីមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគឺជាតំរូវការចាំបាច់ក្នុងការសិក្សាគំរោង និងតំណាក់កាលសាងសង់គំរោងនេះ ។ |
| ០៨ មិថុនា ០៧ | លោក មាស ស៊ីថា | អនុប្រធានខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកោះកុង | - គ្មានការជំទាស់ទេ និងបានស្វាគមន៍ពីការអភិវឌ្ឍគំរោងក្នុងតំបន់ស្ទឹងតាតៃ ។<br>- លោកបានផ្តល់អនុសាសន៍ទៅក្រុមសិក្សាឱ្យធ្វើសហប្រតិបត្តិការល្អជាមួយអង្គការអភិរក្សអន្តរជាតិដែលជាអ្នកទទួលខុសត្រូវក្នុងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់គំរោង ។ |
| ១៤ មិថុនា០៧ | លោក ជ័យ ពេជ្ររតនា | ប្រធានមន្ទីរបរិស្ថាន ខេត្តកោះកុង | - ធនធានព្រៃឈើក្នុងតំបន់គំរោងនៅមានលក្ខខណ្ឌល្អទាំងអស់នេះបើតាមអង្គការអភិរក្សអន្តរជាតិដូច្នេះការសាងសង់វារីអគ្គិសនីនៅទីនេះប្រហែលជាអាចប៉ះពាល់ដល់ព្រៃឈើ ហើយការសិក្សាពីផលប៉ះពាល់នៃធនធានធម្មជាតិគឺត្រូវបានគេតំរូវឱ្យមាន ។<br>- ក្នុងករណីទឹកលិចផ្ទះប្រជាជន និងលិចដីស្រែចំការ គំរោងនឹងស្វែងរកដីសម្បទានសង្គមកិច្ចផ្តល់ឱ្យពួកគេដែលមានតម្លៃប្រហាក់ប្រហែលនូវអ្វីដែលពួកគេបានបាត់បង់ ។<br>- បានស្វាគមន៍គំរោងវារីអគ្គិសនីស្ទឹងតាតៃនេះនិងបានរំពឹងថាគំរោងនឹងផ្តល់ផលប៉ះពាល់វិជ្ជមានច្រើនទៅដល់សេដ្ឋកិច្ចជាតិ ។ |
| ១៤ មិថុនា ០៧ | លោក ប៊ិច ស៊ីយ៉ុន | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកោះកុង | - បានស្វាគមន៍គំរោងវារីអគ្គិសនីស្ទឹងតាតៃដែលអាចផ្តល់ថាមពលអគ្គិសនីឆ្លើយតបទៅនឹងតំរូវការភ្លើងអគ្គិសនីក្នុងប្រទេស ដូចជាក្នុងផែនការមេរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងធនាគារពិភពលោកឆ្នាំ២០០៤ ។<br>- ស្នើឱ្យក្រុមហ៊ុនគ្រោងអនុញ្ញាតឱ្យបុគ្គលិកមន្ទីរធ្វើការក្នុងការសិក្សាសមិទ្ធិលទ្ធភាពព្រមទាំងក្នុងការសិក្សាប្លង់ |

Draft

| | | | |
|---|---|---|---|
| | | | គំរោងពិស្តារ និងដំណាក់កាលសាងសង់ដើម្បីផ្តល់ឱ្យពួកគេនូវឱកាសសំរាប់ការកសាងសមត្ថភាព ។<br>- ចែករំលែកព័ត៌មានជាមួយមន្ទីរផងដែរ ។<br>- រំពឹងថាក្រុមសិក្សាវាយតម្លៃនឹងរៀបចំផែនការបានល្អដោយមានផលប៉ះពាល់បរិស្ថានជាអប្បរមានៅក្នុងតំបន់គំរោងនេះ ។ |
| ២៥ កក្កដា ០៧ | Ms. Xiaozi Liu | Regional Program Officer-MRBM, East Asia Regional Office, Oxfam American | - លោកស្រី លី បានលើកឡើងថាបញ្ហាហេតុប៉ះពាល់ទៅលើឃុំដែលស្ថិតនៅខាងក្រោមខ្សែទឹកពីទំនប់ ជាពិសេសនៅក្នុងតំបន់អណ្តូងមាស តាវែន និងក្នុងស្រុកវីនសៃ នៃខេត្តរតនគីរីដោយប្រតិបត្តិការទំនប់យ៉ាលី ។<br>- ស្នើឱ្យក្រុមហ៊ុនធ្វើគំរោងចូលរួមបញ្ហានេះ និងទៅតាមផែនការគ្រប់គ្រងបរិស្ថានឱ្យបានសមរម្យ ។ |
| ២៥ កក្កដា ០៧ | Ms. Laura Ediger | Regional Research Consultant, Natural Resource Management, Oxfam American | - លោកស្រីបានចែករំលែកបទពិសោធន៍កាលពីមុន១មួយចំនួនទាក់ទងទៅនឹងហេតុប៉ះពាល់ទៅលើជីវចំរុះពីគំរោងវារីអគ្គិសនី ។<br>- លោកស្រីបានស្នើឱ្យម្ចាស់គំរោងធ្វើការស្រាវជ្រាវទៅលើពពួកសត្វនឹងពពួករុក្ខជាតិនៅក្នុងតំបន់គំរោងមុនពេលគំរោង ត្រូវបានសាងសង់ ។ |

អ្នកពាក់ព័ន្ធទាំងអស់ និងប្រជាជនមូលដ្ឋានបានយល់យ៉ាងច្បាស់ពីឈ្មោះគំរោង ដំណាក់កាលរបស់គំរោង និងសមាសភាពរបស់វាក្នុងពេលពិគ្រោះយោបល់ជាសាធារណៈ និងជួបប្រជុំជាមួយក្រុម សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ជាទូទៅប្រជាជនមូលដ្ឋាន និងអ្នកដែលពាក់ព័ន្ធបានស្វាគមន៍គំរោងវារីអគ្គិសនីតាតៃ និងផ្តល់យោបល់ទៅក្រុមសិក្សា ក្រុមហ៊ុនដែលបានរៀបរាប់ខាងលើ ។ យោបល់សំខាន់មួយចំនួន រួមទាំងការផ្តល់ការទូទាត់សំណងយ៉ាងសមរម្យទៅប្រជាជនដែលប៉ះពាល់ដោយផ្ទាល់ដោយសារគំរោងនេះ ។ អ្នកចូលរួមមួយចំនួនចង់ឱ្យក្រុមហ៊ុនធ្វើតាមយ៉ាងម៉ឺងម៉ាត់នូវវិធានការកាត់បន្ថយនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ។ ជាងនេះទៅទៀតអង្គការអន្តរជាតិមួយចំនួនស្នើឱ្យក្រុមហ៊ុនសហការណ៍ល្អជាមួយនឹងរដ្ឋបាលព្រៃឈើដើម្បីការពារព្រៃឈើ និងសត្វព្រៃក្នុងតំបន់គំរោង ។



Draft